# សេចក្តីថ្លែងការណ៍រួម
# ស្តីពី
# អនុសាសន៍របស់គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ លើបទបញ្ជា និង នីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត

គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ បណ្តាញយេនឌ័រ និងអភិវឌ្ឍន៍ បណ្តាញបុរសកម្ពុជា បណ្តុំស្ត្រីកម្ពុជា អង្គការ និងបណ្តាញសង្គមស៊ីវិល ដែលធ្វើការផ្ទាល់នៅតាមសហគមន៍ សង្កេតឃើញថា វិសមភាពយេនឌ័រនៅមានកំរិត ធ្វើឲ្យការចូលរួមរបស់ស្ត្រី និងបុរសនៅពុំទាន់ស្មើភាពគ្នាក្នុងដំណើរការបោះឆ្នោត។ យោងទៅលើបេសកកម្មរបស់ គ.ជ.ប ដែល "ធានាឲ្យមានការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស" ហេតុដូច្នេះហើយ ក្រុមការងារយើងខ្ញុំបានជួបប្រជុំពិភាក្សាចំនួនពីរដង ដោយលើកទី១នៅថ្ងៃទី ២៦ ខែមិថុនា និងលើកទី២នៅថ្ងៃទី ២០ ខែកក្កដា ដើម្បីលើកជាមតិយោបល់ ក្នុងការកែសម្រួល និងបំពេញបន្ថែមលើ សេចក្តីព្រាងនៃ បទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៥នេះ។ ការលើកឡើងជាអនុសាសន៍នេះ ធ្វើឡើងក្នុងគោលបំណង ដើម្បីឲ្យប្រជាពលរដ្ឋកម្ពុជា ទាំងស្ត្រី និងបុរស មានឱកាសស្មើគ្នា ប្រកបដោយសមធម៌ ក្នុងដំណើរការចូលរួមចុះឈ្មោះបោះឆ្នោត។

យើងខ្ញុំសូមដាក់ជូននូវអនុសាសន៍សំខាន់ៗមួយចំនួន ដូចខាងក្រោម ៖

១.សំណូមពរចាត់តាំងគណៈកម្មការចំពោះកិច្ចយេនឌ័រ ក្នុងដំណើរការនៃការចុះឈ្មោះបោះឆ្នោតដើម្បីធានាឲ្យដំណើរការនៃការចុះឈ្មោះបោះឆ្នោតផ្តល់ឱកាសអោយស្មើភាពចំពោះ ស្ត្រី ជនពិការ និងជនជាតិដើមភាគតិច។

២. គណកម្មការជ្រើសរើសក្រុមចុះឈ្មោះបោះឆ្នោតត្រូវមានយ៉ាងតិចស្ត្រីមួយរូប។

៣. ក្រុមការងារចុះឈ្មោះបោះឆ្នោតត្រូវមានយ៉ាងតិចស្ត្រីមួយរូប ទៅពីររូប។

៤. គ្រប់តួនាទីដែលត្រូវជ្រើសរើសត្រូវតែផ្សព្វផ្សាយឲ្យបានទូលំទូលាយក្នុងរយៈពេល១០ (ដប់) ថ្ងៃ យ៉ាងតិចនៃថ្ងៃធ្វើការ។ ករណីគ្មានបេក្ខនារីដាក់ពាក្យអំឡុងពេលខាងលើត្រូវពន្យាពេល ៥ថ្ងៃ នៃថ្ងៃធ្វើការបន្ថែមទៀត។

៥. រាល់ការផ្សព្វផ្សាយជ្រើសរើស ស្ត្រី ជនពិការ និងជនជាតិដើមភាគតិចត្រូវបានលើកទឹកចិត្តឲ្យចូលរួម។

៦. រាល់ក្រុមសង្កេតការណ៍ លើការងារបោះឆ្នោត ទាំងសង្គមស៊ីវិល និងគណបក្សនយោបាយ ត្រូវតែមានស្ត្រីចូលរួមចំនួន ៥០%

៧. ស្នើសុំឲ្យរយៈពេលនៃការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត ត្រូវធ្វើចាប់ពីថ្ងៃទី ០១ ខែ មេសា រហូតដល់ ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១៦។

**ទំនាក់ទំនងព័ត៌មានបន្ថែម៖**

*-កញ្ញា សេង រាសី មន្ត្រីសម្របសម្រួលគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ ០១៧ ៩៣៣ ៣៣៦*

*- លោកស្រី សឺនកេត សិរីលក្ខណ៍ មន្ត្រីអប់រំ និងយេនឌ័រនៃអង្គការខុមហ្វ្រែល ០១៧ ៤៩៤ ០០៤*